

# ដំណឹងមរណៈភាព

*យើងខ្ញុំក្នុងនាមគ្រួសារ កំពុងទទួលរងនូវមហាទុក្ខដ៏ក្រៀមក្រំ ដោយលោក* **ថាច់ បុល ហៅ ភោន** THACH BOL (PON) *ជាស្វាមី-ឪពុក បានទទួលមរណៈភាព នាថ្ងៃអង្គារ ទី២៣ ខែធ្នូ ឆ្នាំ២០០៨ ដោយពោគាពាធ វេលាម៉ោង ៦ព្រឹក ក្នុងជន្មាយុ៤២ឆ្នាំ នៅរដ្ឋផ្លរីដា អាមេរិក។*

*យើងខ្ញុំទាំងអស់គ្នា ដែលត្រូវជាភរិយា-កូន និងសាច់ញាតិនៃសព នឹងរៀបចំពិធីបុណ្យឈាបនកិច្ច ទុក្ខិណានុប្បទាន, ធាកមហាបង្សុកូល ទៅតាមលក្ខណៈប្រពៃណីជាតិខ្មែរ ដើម្បីឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាក្ខន្ធសព លោក **ថាច់ បុល ហៅ ភោន** ដែលទើបតែធ្វើកាលកិរិយាទៅកាន់បរលោកនាយនាពេលថ្មីៗនេះ។*

*លោក* **ថាច់ បុល ហៅ ភោន** *ជាសកម្មជនសហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំរដ្ឋផ្លរីដា ប្រសូតិនៅឆ្នាំ១៩៦៦ ភូមិតាសេក ស្រុកវិញចូវ ខែត្រឃ្លាំង កម្ពុជាក្រោម។ បិតានាម* Thach Phuong *មាតានាម* Thach Thi Det *បច្ចុប្បន្នកំពុងរស់នៅកម្ពុជាក្រោម។ លោក **ថាច់ បុល ហៅ ភោន** ដែលមានភរិយានាម* **ថាច់ ធី ប្រាឌ្ត** *និងមានបុត្រាបុត្រី ចំនួន២នាក់ កូនទី១ ឈ្មោះ* **ថាច់ បូរ៉ា** *ភេទប្រុស កូនស្រីពៅឈ្មោះ* **ថាច់ ធី បូលីណា** *ព្រមទាំងមានបងប្អូនរួមផ្ទៃចំនួន៩នាក់ ១.លោក ថាច់ បុល ហៅ ភោន (ស្លាប់) នៅសហរដ្ឋអាមេរិក, ២. អ្នកស្រី ថាច់ ធី ភីន សព្វថ្ងៃរស់នៅអាមេរិក, ៣. លោក ថាច់ វិន រស់នៅសហរដ្ឋអាមេរិក, ៤. លោក ថាច់ វឿន បច្ចុប្បន្នរស់នៅកម្ពុជាក្រោម, ៥.លោក ថាច់ សែន, ៦. លោក ថាច់ សី, ៧.អ្នកស្រី ថាច់ ធី ឡាយ, ៨.លោក ថាច់ លី និងអ្នកស្រី ថាច់ ធី លីណា។*

*ដំណឹងដ៏ក្រៀមក្រំនេះ សូមប្រគេន-ជំរាបជូន នឹងគោរពអញ្ជើញ ដល់លោក លោកស្រី និងបងប្អូនញាតិមិត្តជិតឆ្ងាយ មេត្តាចូលរួមរំលែកមរណៈទុក្ខ និងញ៉ាំងកម្មវិធីបុណ្យបូជាសព តាមប្រពៃណី ព្រះពុទ្ធសាសនា ដែលនឹងប្រព្រឹត្តទៅ* ***<u>នៅថ្ងៃសុក្រ-សៅរ៍ ទី២៦-២៧ ខែធ្នូ ខាងមុខនេះ</u>*** *និងដើម្បីទទួលយកនូវកុសលផលបុណ្យ ក្រកបដោយធម្មសង្វេគរៀងៗខ្លួន។*

*ឆ្លៀតឧកាសដ៏ក្រៀមក្រំនេះ តាងនាមគណៈកម្មការនាយក និងសមាជិក-កា នៃសហព័ន្ធខ្មែរកម្ពុជាក្រោម មានសេចក្តីសោកស្តាយ និងសូមចូលរួមរំលែកមរណៈទុក្ខជាមួយនឹងក្រុមគ្រួសារនៃសព ព្រមទាំងសូមបួងសួងដល់វិញ្ញាណក្ខ័ន្ធសព លោក **ថាច់ បុល ហៅ ភោន** ឲ្យបានទៅចាប់បដិសន្ធិក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។*

*<u>ព័ត៌មានបន្ថែមសូមទាក់ទង:</u>* **MR. LAM THANH TAM TEL: (407) 421-9786**

# រូបថតអនុស្សាវរីយ៍ លោក ថាច់ បុល ហៅ គោន ជាមួយនឹងក្រុមយុវជនខ្មែរកម្ពុជាក្រោម







លោក ថាច់ បុល ហៅ គោន (សញ្ញាព្រួយជាប់នឹងទងជាត) ថតនៅទីក្រុងឡាអេ ប្រទេសហូឡង់ កាលពីឆ្នាំ២០០៦